# តើនរណាជាជនបន្ទាប់?

**ដោយ ប៊ែត វ៉ាន់ស្កាក់**

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

កិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានដាក់ភារកិច្ចឲ្យអង្គជំនុំជម្រះ«នាំមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវខ្ពស់លើឧក្រិដ្ឋកម្ម»ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមមកវិនិច្ឆ័យទោស ។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែផ្តោតការវិនិច្ឆ័យទោសរបស់ខ្លួនលើជនជាប់ចោទពីរប្រភេទគឺ : មេដឹកនាំជាន់ខ្ពស់ និងជនដែល«ទទួលខុសត្រូវខ្ពស់បំផុត» សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ នាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះមានជនសង្ស័យចំនួនប្រាំរូបដែលកំពុងតែជាប់ឃុំខ្លួន ដែលក្នុងនោះជនសង្ស័យបួនរូបជាជនជាប់ចោទប្រភេទទីមួយ ។ ជនជាប់ចោទទាំងបួនរូបមានដូចជា នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ គឺជាជនតំណាងឲ្យសមាជិក«គណៈមជ្ឈិម»របស់បក្សកុម្មុយនីស្តកម្ពុជា និងតំណាងឲ្យអ្នកស្មោះស្ម័គ្រនឹង ប៉ុល ពត ។ ជនជាប់ចោទទីប្រាំឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលមិនមែនជាមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា គឺជាជនជាប់ចោទប្រភេទទីពីរ ។ ភស្តុតាងប្រឆាំងនឹងជនជាប់ចោទរូបនេះ ដែលក្នុងនោះរួមមានការសារភាពដោយខ្លួនឯងបានបង្ហាញថា ឌុច គឺពិតជាជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដោយសារតែ ឌុច មានតួនាទីគ្រប់គ្រងលើប្រព័ន្ធធ្វើទារុណកម្ម និងសម្លាប់របស់មន្ទីរ ស-២១ ជាមន្ទីរឃុំឃាំងមួយក្នុងចំណោមមន្ទីរឃុំឃាំងក្នុងប្រទេសជាច្រើនទៀត ដែលត្រូវបានបង្កើតឡើងដើម្បីសួរចម្លើយ និងកម្ទេចខ្មាំងបដិវត្តន៍ ។ ក្រោយពីការនាំខ្លួនជនជាប់ចោទទាំងប្រាំរូបនេះមកឃុំឃាំងរួចមក យើងមិនទាន់ឃើញជនជាប់ចោទផ្សេងទៀតត្រូវបានគូសបញ្ជាក់ពីអត្តសញ្ញាណនៅឡើយទេ ។

នេះគឺជារឿងគួរឲ្យសោកស្តាយមួយ ។ សហគមន៍អន្តរជាតិបានរៀបចំខ្លួនរួចជាស្រេចក្នុងការផ្តល់ជំនួយដ៏ធំក្នុងផ្នែកធនធាន បុគ្គលិកបំរើការងារ ការឧបត្ថម្ភផ្នែកឯកសារ អ្នកជំនាញផ្នែកបច្ចេកទេសជាដើមដល់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាឲ្យបាននូវការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលបានកើតមាននៅក្នុងរបបខ្មែរក្រហម ។ វាអាចក្លាយជារឿងមួយដ៏អាម៉ាស់ប្រសិនបើការផ្តល់ជំនួយដ៏ធំនេះទទួលបានត្រឹមតែការវិនិច្ឆ័យទោសលើជនជាប់ចោទតែប្រាំរូប ។

ជាក់ស្តែង ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចវិនិច្ឆ័យទោសតែជនជាប់ចោទប្រាំរូបនេះមែននោះ អង្គជំនុំជម្រះនេះនឹងបានត្រឹមតែបង្ហាញពីទិដ្ឋភាពមិនពេញលេញនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ ។ ឧក្រិដ្ឋកម្មដែលមានលក្ខណៈជាប្រព័ន្ធនិងធំធេងទាមទារឲ្យមានការចូលរួមពីបុគ្គលជាច្រើនដែលមានកម្រិតទទួលខុសត្រូវខុសៗគ្នា ។ បើទោះបីជាគណៈមជ្ឈិមបានបង្កើតគោលនយោបាយដែលមិនត្រឹមត្រូវ និងមិនមានប្រយោជន៍ដើម្បីសម្គាល់អត្តសញ្ញាណរបស់ខ្លួនជាខ្មែរក្រហមក៏ដោយ ក៏ការអនុវត្តគោលនយោបាយទាំងនោះគឺជាការទទួលខុសត្រូវរបស់កម្មាភិបាលថ្នាក់កណ្តាលដូចជា ឌុច ជាដើម ។ ម្យ៉ាងវិញទៀត ឯកសារស្រាវជ្រាវបានគូសបញ្ជាក់ថា កម្មាភិបាលខ្មែរក្រហមទទួលបាននូវសិទ្ធិអំណាចក្នុងការអនុវត្តការងារ ដោយទទួលបញ្ជាសម្ងាត់ពីគណៈមជ្ឈិម ។ ដូច្នេះហើយបានជាមានខេត្តខ្លះ ឬភូមិខ្លះទទួលរងទុក្ខលំបាកវេទនាខុសៗពីគ្នា ។ ការបង្ហាញនូវភស្តុតាងស្តីពីការទទួលខុសត្រូវដ៏ពេញលេញនៅក្នុងប្រព័ន្ធឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម អាចនឹងធានាថា ប្រជាជនកម្ពុជានឹងទទួលបានការយល់ដឹងពីបែបបទនៃការគោរពតាមបញ្ជា និងអំពើហិង្សាដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ការធ្វើបែបនេះធានាបានថា អង្គជំនុំជម្រះវិសាមញ្ញនឹងបន្តរុករកដំណើរការវិវត្តន៍នៃប្រវត្តិសាស្ត្រជាតិ ដែលកិច្ចប្រឹងប្រែងនេះអាចនឹងត្រូវបានរារាំងដោយជនមួយចំនួនដែលបដិសេធមិនទទួលស្គាល់ ឬជនដែលចង់លុបបំបាត់អតីតកាលនៃប្រវត្តិសាស្ត្រនេះ ។

ដោយសារមូលហេតុទាំងអស់នេះហើយ ទើបសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះគួរតែបន្តដំណើរការវិនិច្ឆ័យទោសជនដែលមានឋានៈដូចជា ឌុច : ជាជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសាហាវឃោរឃៅនៅក្នុងសហគមន៍ដែលខ្លួនរស់នៅ ។ វិសាលភាពនៃការវិនិច្ឆ័យទោសដ៏មានកម្រិតរបស់អង្គជំនុំជម្រះមិនគួរត្រូវបានយកមកអនុវត្ត ដើម្បីជាលេសសម្រាប់បន្តស្វែងរកការទទួលខុសត្រូវដែលមិនពេញលេញនោះទេ ផ្ទុយទៅវិញ អង្គជំនុំជម្រះគួរតែបន្តវិនិច្ឆ័យទោសលើជនទាំងឡាយដែលមានភស្តុតាងចោទប្រកាន់គ្រប់គ្រាន់ ។ រចនាសម្ព័ន្ធជាពីរថ្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញ ដែលផ្តល់សិទ្ធិអំណាចស៊ើបអង្កេតជាអាទិភាពដំបូងដល់សហព្រះរាជអាជ្ញា ហើយអាទិភាពទីពីរដល់សហចៅក្រមស៊ើបអង្កេតនោះ នឹងធានាថា មានតែជនដែលមានភស្តុតាងចោទប្រកាន់គ្រប់គ្រាន់តែប៉ុណ្ណោះ ដែលនឹងត្រូវនាំមកវិនិច្ឆ័យទោសចំពោះមុខអង្គសវនាការ ។ ដំណើរការនីតិវិធីវិនិច្ឆ័យទោសអាចនឹងផ្តល់លទ្ធភាពគួរឲ្យជឿទុកចិត្តបានលុះត្រាតែដំណើរការនីតិវិធីនេះប្រព្រឹត្តទៅដោយសមភាព និងយុត្តិធម៌ ។ ហើយវាអាចនឹងផ្តល់ជាលទ្ធផលគួរឲ្យជឿទុកចិត្តបាន លុះត្រាតែដំណើរការនីតិវិធីនេះអាចផ្តល់នូវភាពផ្សះផ្សារដ៏ពេញលេញ និងមាន

ន័យមួយសម្រាប់សង្គមជាតិកម្ពុជា ។ ដោយសារតែគ្មានយន្តការផ្សេងទៀតដែលប្រទេសកម្ពុជាគិតថាខ្លួនអាចទទួលបាននូវយុត្តិធម៌អន្តរកាល ដូច្នេះហើយបានជាអង្គជំនុំជម្រះវិសាមញ្ញបានដើរតួជាអ្នកផ្តល់ឱកាសមួយដល់ប្រទេសកម្ពុជាដើម្បីជួយឲ្យប្រជាជនកម្ពុជាបានដឹងពីការពិតដ៏ពេញលេញមួយថា តើហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តឧក្រិដ្ឋកម្ម និងតើខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះដោយរបៀបណា ។ ក្រោយពីការទទួលរងនូវភាពលំបាកវេទនាអស់ជាច្រើនឆ្នាំកន្លងមក ប្រជាជនកម្ពុជាសមនឹងទទួលបានអ្វីត្រឡប់មកវិញ ។